**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ: ១៣៤៣កបទ.សអ.បល

# សេចក្តីជូនដំណឹង

សូមជូនដំណឹងដល់សាធារណជនឲ្យបានជ្រាបថា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នឹងរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីក្របខណ្ឌ "ក" ចំនួន ១៧នាក់ សម្រាប់ឆ្នាំ២០២០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃសៅរ៍ ៧កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២០ លើមុខជំនាញដូចខាងក្រោម៖

- ភាសាអង់គ្លេស: ០៨ នាក់
- ព័ត៌មានវិទ្យា: ០៦ នាក់
- ការទូតសេដ្ឋកិច្ច: ០៣ នាក់

**បេក្ខជន បេក្ខនារី ត្រូវមានលក្ខណៈសម្បត្តិដូចតទៅ៖**

១. មានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឡើងលើមុខជំនាញ៖ ភាសាអង់គ្លេស ទំនាក់ទំនងអន្តរជាតិ សិក្សាសកល នីតិសាស្ត្រ សេដ្ឋកិច្ចនយោបាយអន្តរជាតិ ពាណិជ្ជកម្មអន្តរជាតិ ហិរញ្ញវត្ថុ គណនេយ្យ ស្ថាបត្យកម្ម និងព័ត៌មានវិទ្យា។

២. ត្រូវមានកម្រិត IELTS 5.5 ឡើង លើគ្រប់មុខជំនាញ លើកលែង ព័ត៌មានវិទ្យា

៣. មានសញ្ជាតិខ្មែរ និងសុខភាពល្អ

៤. អាយុ៖

- មិនលើស ៣៥ឆ្នាំ សម្រាប់សញ្ញាបត្របរិញ្ញាបត្រ (គិតត្រឹមថ្ងៃប្រឡង)
- មិនលើស ៤០ឆ្នាំ សម្រាប់សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ (គិតត្រឹមថ្ងៃប្រឡង)
- មិនកំណត់អាយុសម្រាប់សញ្ញាបត្រថ្នាក់បណ្ឌិត

៥. ជនពិការ ដែលមានសមត្ថភាពសមស្រប និងបេក្ខនារី ត្រូវបានលើកទឹកចិត្ត ។

<u>បញ្ជាក់</u> ៖ - សញ្ញាបត្រពីក្រៅប្រទេស ត្រូវមានលិខិតបញ្ជាក់ពីនាយកដ្ឋានឧត្តមសិក្សា និងពុំចាំបាច់មាន IELTS ទេ
- សញ្ញាបត្រក្នុងប្រទេស៖ ត្រូវតែជាភាសាខ្មែរ និងបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានចំពោះច្បាប់ចម្លង ព្រមទាំងភ្ជាប់មកជាមួយនូវច្បាប់ដើម

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

- បេក្ខជន បេក្ខនារី ត្រូវបំពេញសំណុំបែបបទ៖ ពាក្យសុំចុះឈ្មោះប្រឡងជ្រើសរើសមន្ត្រី ចំនួន ០១ ច្បាប់ ជីវប្រវត្តិសង្ខេបចំនួន ០១ ច្បាប់ សលាកប័ត្រឯកត្តជន ០១ ច្បាប់ និងបង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡងចំនួន ០១ ច្បាប់
- ត្រូវបញ្ជាក់អំពីភាពគ្មានទោស (លិខិតថ្កោលទោស) ពីក្រសួងយុត្តិធម៌ បន្ទាប់ពីបេក្ខជន បេក្ខនារី ប្រឡងជាប់ស្ពាពរ
- ការដាក់ពាក្យប្រឡងតម្រូវឲ្យបង់ប្រាក់ចំនួន ២០.០០០ រៀល ។

**<u>វិញ្ញាសាប្រឡង</u>** ៖

វិញ្ញាសាសរសេរ និងវិញ្ញាសាសួរផ្ទាល់មាត់៖ ភាសាអង់គ្លេស ការទូតសេដ្ឋកិច្ច និងព័ត៌មានវិទ្យា។

សាធារណជន ដែលមានបំណងចូលរួមប្រឡង សូមទាញយកពាក្យស្នើសុំសិទ្ធិប្រឡង តាមរយៈគេហទំព័រក្រសួង www.mfaic.gov.kh និងទំព័រហ្វេសប៊ុកក្រសួង www.facebook.com/mfaic.gov.kh។

ការទទួលពាក្យ នឹងត្រូវចាប់ផ្តើមពីថ្ងៃផ្សាយដំណឹងនេះ ហូតដល់ថ្ងៃចន្ទ **៩រោច ខែមាឃ** ឆ្នាំកុរ ឯកស័ក ព.ស.**២៥៦៣** ត្រូវនឹងថ្ងៃទី**១៧** ខែកុម្ភៈ ឆ្នាំ**២០២០** រៀងរាល់ម៉ោងធ្វើការ នៅនាយកដ្ឋានបុគ្គលិក នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលមានអាសយដ្ឋាន៖ អគារលេខ ៣ វិថី សម្តេច ហ៊ុន សែន សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ។

**<u>បញ្ជាក់</u>៖** ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានសិទ្ធិជម្រុះបេក្ខជន បេក្ខនារី ដែលមិនបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ មិនអោយចូលរួមប្រឡង។

ថ្ងៃ ចន្ទ ៥កើត ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ភ្នំពេញ ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០១៩

**ជ.ប្រធានគណៈកម្មការរៀបចំការប្រឡង**

**អនុប្រធាន**

**អ៊ុច បូររិទ្ធ**

<u>ចម្លងជូន៖</u>
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ឯកសារ - កាលប្បវត្តិ